# ឧត្តមភាពស្ត្រីតាមរយៈតំណាលកថាប្រជាប្រិយមួយចំនួន

*ដោយ* : **បណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*នៅលើពិភពលោកយើងនេះ ប្រទេសនីមួយៗតែងតែមានវប្បធម៌-អរិយធម៌ប្រចាំជាតិរបស់ខ្លួន ហើយវប្បធម៌-អរិយធម៌នៃជាតិនោះ រមែងតែងតែស្របទៅនឹងផ្នត់គំនិត ទស្សនៈរបស់ប្រជាជាតិមួយជានិច្ច។ យ៉ាងណាមិញ ប្រទេសកម្ពុជាយើងក៏ជាប្រទេសមួយដែលមានវប្បធម៌-អរិយធម៌ចំណាស់និងសម្បូរបែបផងដែរ។ ទន្ទឹមនឹងភាពចំណាស់នោះ ដំបូងឡើយកម្ពុជាក៏ជាអាណាចក្រមួយដែលមានស្ត្រីជាបឋមក្សត្រក្នុងការដឹកនាំសង្គមផងដែរ ហើយដោយសារតែកត្តានេះហើយ ទើបផ្នត់គំនិតខ្មែរតាំងពីដើមមកតែងតែឱ្យតម្លៃនិងគោរពចំពោះស្ត្រីភេទ។ នៅក្នុងសង្គមខ្មែរ មិនថាពីសម័យបុរាណឬមកដល់សម័យបច្ចុប្បន្ននេះទេ ការឱ្យតម្លៃទៅលើស្ត្រី(មេ) នៅតែជារឿងមួយប្រកបដោយឧត្តមភាពដ៏ចម្បងនិងគួរឱ្យយកចិត្តទុកដាក់។ ដូច្នេះស្ត្រីបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការជួយអភិវឌ្ឍសង្គម ក៏ដូចជាមានតួនាទីយ៉ាងសំខាន់ដែលមិនអាចខ្វះបាន មិនថានៅក្នុងគ្រួសារឬសង្គមឡើយ(ស្ត្រីដៃ១០០)។*

*យើងដឹងហើយថា តាំងពីសម័យបុរាណកាលមក ព្រលឹងមាតាធិបតេយ្យជាព្រលឹងជឿនលឿននិងរឹងមាំ ព្រមទាំងបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិតប្រជាជននិងក្នុងសង្គមនោះ បានស្ថិតស្ថេរជារៀងរហូតដល់សព្វថ្ងៃនេះ។ ការឱ្យតម្លៃទៅលើស្ត្រី គឺជារឿងមួយដែលគេបានផ្តោតការយកចិត្តទុកដាក់ខ្ពស់ បើទោះបីជាស្ត្រីជាភេទមានកម្លាំងទន់ខ្សោយជាងបុរសក្តី គឺស្ត្រីនៅតែដើរតួនាទីយ៉ាងសំខាន់មិនអាចខ្វះបានឡើយ រហូតដល់មានពំនោលពោលថា ស្ត្រីជាកម្លាំងចលករ ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចគ្រួសារនិងសង្គមជាតិក្នុងការជួយទ្រទ្រង់គ្រួសារនិងសង្គមឱ្យមានការអភិវឌ្ឍ និងស្ត្រីជាដៃគូជាមួយនឹងបុរសដែលមិនអាចខ្វះបាន។ ជាតឹកតាងតាមរយៈឯកសារប្រវត្តិសាស្ត្រ ក៏ដូចជាតាមរយៈទំនៀមទម្លាប់ ប្រពៃណី ជីវភាពរស់នៅក្នុងសង្គម ស្នាដៃអក្សរសិល្ប៍ ជាពិសេសគឺតាមរយៈស្នាដៃ*

អក្សរសិល្ប៍ប្រជាប្រិយនិយាយជារួម និង និយាយដោយឡែកគឺតំណាលកថា ប្រជាប្រិយ សុទ្ធតែបានបង្ហាញយ៉ាងប្រត្យក្ស ពីការឱ្យតម្លៃ លើកតម្កើងនិងយកចិត្តទុកដាក់ចំពោះស្ត្រី។ ជាក់ស្តែងក្នុងស្នាដៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរមួយចំនួន ជាពិសេសតំណាលកថាប្រជាប្រិយដែលកើតចេញពីការនិទានតៗគ្នា ពីមាត់មួយទៅមាត់មួយ ពីតំបន់មួយទៅតំបន់មួយ ក៏បានបង្ហាញពីចំណុចជាច្រើនដែលទាក់ទងទៅនឹងការលើកតម្កើងនិងផ្តល់តម្លៃចំពោះស្ត្រី ពោលគឺបង្ហាញពីឧត្តមភាពនៃស្ត្រី។ តើតំណាលកថាប្រជាប្រិយខ្មែរបានបកស្រាយបង្ហាញពីឧត្តមភាពស្ត្រីដូចម្តេចខ្លះ?

មុននឹងយើងធ្វើការបកស្រាយវែកញែកពីឧត្តមភាពស្ត្រីតាមរយៈនិទានកថាសង្គមនេះ យើងគួរយល់នូវពាក្យគន្លឹះមួយចំនួន គឺ ឧត្តមភាព ស្ត្រី និងតំណាលកថាប្រជាប្រិយ ជាមុនសិន។

## ១- បញ្ញត្តិ ស្តីពី ឧត្តមភាព ស្ត្រី និងតំណាលកថាប្រជាប្រិយ

### ១.១- ឧត្តមភាព

តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ឧត្តម អ៊ុត-ដំ សំ. បា. (គុ.) ខ្ពស់, ខ្ពង់ខ្ពស់; កន្ទង់; ល្អ; ប្រសើរ; ថ្លៃថ្លា; បរិបូណ៌; សម្បូណ៌ : ថ្នាក់ឧត្តម ថ្នាក់ខ្ពស់។[1]

ឧត្តមភាព ភាពឧត្តម ភាពខ្ពង់ខ្ពស់ ភាពល្អ ភាពប្រសើរ...។

### ១.២- ស្ត្រី

តាមវចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យពាក្យ "ស្ត្រី" ថា ជាគូនឹងបុរស ត្រូវប្រើឱ្យស្របគ្នាថា បុរស ស្ត្រី ប្រុសស្រី កុំប្រើ បុរសស្រី ប្រុសស្ត្រីដូច្នេះឡើយ។[2]

ន័យទី១ "ស្រី" ពាក្យសម្រាប់ប្រើជាសាធារណៈឃ្លាតមកពីពាក្យសំស្ក្រឹតថា ស្ត្រី គឺមនុស្សជាតិដែលមានភេទទីទៃពីប្រុស (បុរិសៈ ឬ បុរស) ទីទៃពីខ្ទើយ(បណ្ឌក) ត្រូវប្រើឱ្យស្របគូគ្នាថា ស្រី ប្រុស ឬ ប្រុស ស្រី កុំប្រើថាស្ត្រីប្រុស ឬប្រុសស្ត្រីឡើយ ត្រូវប្រើថា បុរសស្ត្រី ឬ ស្ត្រីបុរសទើបស្របគ្នា : ប្រុសស្រី

[1] ពុទ្ធសាសនបណ្ឌិត្យ **វចនានុក្រមខ្មែរ ភាគ១ និង២** ទំព័រ៧៣៦។

[2] ពុទ្ធសាសនបណ្ឌិត្យ **វចនានុក្រមខ្មែរ** ដ.ឯ.ម ទំព័រ ៧៣៦។

ជាប្តីប្រពន្ធ បុរសស្រ្តីជាស្វាមីភរិយា(ប្រើពាក្យស្របគ្នាយ៉ាងនេះទើបសម)។[៣]

ន័យទី២ ពាក្យ "ស្រី" (ន.) សិរី។ ខ្មែរច្រើនប្រើជាពាក្យរួមខាងដើមសព្ទដទៃ ដូចជា ព្រះស្រីសព៌េជ្ញ ព្រះសព៌េជ្ញមានសិរី (ព្រះសព្វញ្ញុពុទ្ធ)។[៤]

តាមទស្សនៈពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងបានត្រាស់សម្តែងថា "ស្រ្តី គឺមានសិទ្ធិស្មើនឹងបុរសដែរនៅក្នុងកិច្ចការងារផ្សេងៗ។ នៅពេលដែលព្រះនាងមល្លិកាប្រសូត្របានបុត្រី ព្រះមហាក្សត្របាសិនាទី មានព្រះទ័យមិនសប្បាយចិត្តទេក៏យាងទៅក្រាបទូលព្រះសម្មាសម្ពុទ្ធ។ ព្រះបរមគ្រូក៏លួងលោមមហាក្សត្រថា កូនស្រីប្រសើរ ថ្លៃថ្នូរជាងកូនប្រុសទៅទៀត "។[៥]

លោក សរ សារុន បានអះអាងថា" ស្រ្តី គឺជាអ្នករៀបចំកិច្ចការផ្ទះ និងជាមេគ្រួសារដ៏ចំណាន ដែលមិនអាចអត់បាន ។ បើយើងសម្លឹងមើលទិដ្ឋភាពសង្គមខ្មែរ គឺមានសុភាសិតជាច្រើនដែលលើកតម្លៃរបស់ស្រ្តី ជាអ្នកមានគុណធម៌ ជាកម្លាំងគ្រឹះរបស់គ្រួសារ ជាអ្នកថែរក្សា បំប៉នគ្រួសារឱ្យមានស្នេហភាព សុភមង្គល ដូចមានសុភាសិតខ្មែរមួយឃ្លាលោកបានពោលឡើងថា៖ "ស៊ូស្លាប់បា កុំឱ្យស្លាប់មេ ស៊ូលិចទូកកណ្តាលទន្លេ កុំឱ្យតែភ្លើងឆេះផ្ទះ"។[៦]

តាមទស្សនៈរបស់លោក ប្រាជ្ញ ជុំ បានឱ្យនិយមន័យថា ស្រ្តី គឺជាមនុស្សម្នាក់ដែលមានគុណលើមនុស្សទាំងអស់ ។[៧]

តាមពាក្យអង់គ្លេសថា "Woman" នៅក្នុងវចនានុក្រមអង់គ្លេសOxford Advanced Learner's Dictionary បានឱ្យដឹងថា ស្រី ស្រ្តី លក្ខណៈដូចស្រី ត្រូវនឹង Woman: an adult female person។[៨]

---

[៣] ពុទ្ធសាសនបណ្ឌិត្យ **វចនានុក្រមខ្មែរ** ដ.ឯ.ម ទំព័រ ៧៥៧។

[៤] ពុទ្ធសាសនបណ្ឌិត្យ វចនានុក្រមខ្មែរ ដ.ឯ.ម ទំព័រ ៧៥៨។

[៥] ហេមា កោលាកិកកេ ពុទ្ធសាសនា សិទ្ធិស្ត្រី និងសិទ្ធិមនុស្ស ឆ្នាំ១៩៩៦។

[៦] សរ សារុន ល្បងសិក្សា សង្គមវិជ្ជាខ្មែរ ភាគ២ ឆ្នាំ ១៩៧៣- ១៩៧៤ ទំព័រ៤៧។

[៧] ញូ ស្រៀន តម្លៃអប់រំស្ត្រីខ្មែរតាមរយៈសុភាសិតច្បាប់ស្រី របស់អ្នកឧកញ៉ា សុត្តន្តប្រីជាឥន្ទ្រ ឆ្នាំ២០១៧ ទំព័រ ១៦។

[៨] Oxford Advanced Learner's Dictionary New Edition page746.

តាមទ្រឹស្តីរបស់លោក ប្លាតុង បានឱ្យនិយមន័យ "ស្ត្រី" ថា ស្ត្រី គឺជាមាតារបស់មនុស្ស ហើយជាម្ចាស់លើពិភពលោកទាំងមូល។ ប្រសិនបើគ្មានស្ត្រីទេនោះ ម៉្វះអ្វីៗក្នុងលោកក៏គ្មានដែរ ។[៩]

តាមទ្រឹស្តីលោក អារីស្តូត (Aristotle: 384-322Bc) បានឱ្យន័យថា "ភាពសកម្មរបស់ស្ត្រីនៅក្នុងការបង្កើតជីវិតមួយដោយបានផ្តល់នូវរូបកាយ(ពពោះ) រីឯអសកម្មរបស់ស្ត្រី គឺមិនមានលទ្ធភាពដើម្បីបង្កើតទឹកកាម(Semen)ដូចបុរស។ គាត់បានលើកឡើងពីគោលការណ៍សកម្មតែមួយគត់របស់ស្ត្រី គឺការមានផ្ទៃពោះដែលមិនអាចខ្វះបានឡើយដើម្បីបង្កើតឱ្យបាននូវមនុស្សជំនាន់ក្រោយ ប្រសិនបើគ្មានការចូលរួមពីសំណាក់ស្ត្រី ក៏គ្មានមនុស្សដែរ គាត់មានជំនឿជាក់ថាធម្មជាតិមិនត្រឹមតែញ៉ាំងឱ្យមានភាពខុសប្លែកគ្នាខាងរូបរាងរវាងបុរសនិងស្ត្រីប៉ុណ្ណោះទេ ព្រមទាំងញ៉ាំងឱ្យគេទទាំងពីរមានការខុសប្លែកគ្នាខាងខួរក្បាលទៀតផង"។[១០]

តាមទ្រឹស្តីពីតាគ័រ (Pythagore: 571-497BC) បានអះអាងថា " ស្ត្រី និងបុរស គឺជាចំណុចសុក្រិត្យបំផុត ជាមូលដ្ឋានសម្រាប់ពិចារណាគឺ ស្ត្រី និងបុរស ត្រូវតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធដែលមិនអាចកាត់ផ្តាច់បាន"។[១១]

ជាសរុបសេចក្តី ស្ត្រី ឬស្រី បានក្លាយមកពីពាក្យ សិ+រី សិរីមានន័យថាមង្គលសេចក្តីសុខ សេចក្តីចម្រើន ជាលំអដែលគួរឱ្យស្រឡាញ់ ជាប្រភពសិរីសួស្តីក្នុងគ្រួសារ ឬមានន័យម្យ៉ាងទៀតថា រីករាយស្រស់ស្រាយ ញញឹមញញែម បានជួបហើយនឹកមិនភ្លេចជានិមិត្តរូបនៃទឹកសន្សើមស្រោចស្រពលើរុក្ខជាតិទាំងឡាយនៅលើផែនដីឱ្យមានជីវិតរស់នៅជាអចិន្ត្រៃយ៍"។ នៅក្នុងសង្គមខ្មែរ ប្រជាជនយើងចាត់ទុកស្ត្រី ជាមង្គល និងជាអធិបតីក្នុងគ្រួសារ។ ទ្រឹស្តីជាមូលដ្ឋាននៃសុភមង្គលរបស់គ្រួសារនីមួយៗគឺដោយសារមានកូនស្រីល្អ ប្រពន្ធល្អ ម្តាយល្អ។ ចាប់តាំងពីសម័យដើមរហូតមកដល់សព្វថ្ងៃនេះ ឥទ្ធិ-ពលនៃព្រលឹងមាតាធិបតេយ្យបានរស់នៅ បន្តដោយ

[៩] សុខ សុត្ថាល **មហាទស្សនវិទូ និងទស្សនៈវិជ្ជាក្នុងលោក** ភ្នំពេញ ឆ្នាំ១៩៧១ ទំព័រ១៦៩។

[១០]សុខ គាង ទ្រឹស្តីនយោបាយ ទំព័រ២១។

[១១]Woman’s studies encyclopedia volime III First printed by Gelen Tierney 1993 USA page33.

ប្រជាជនខ្មែរ។ សង្គមខ្មែរចាត់ទុកព្រលឹងមាតាធិបតេយ្យជាព្រលឹងជឿនលឿន ហើយឯកភាពគ្នា ថែរក្សាការពារ តាមរយៈជំនឿទំនៀមទម្លាប់ ប្រពៃណី និងអក្សរសាស្ត្រខ្មែរជាដើម។ អ្នកស្រាវជ្រាវបានចាត់ទុកថាមាតាធិបតេយ្យជាព្រលឹងរបស់ខ្មែរក្នុងចំណោមព្រលឹងជាច្រើនទៀត ដែលស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ។ ព្រលឹងនេះត្រូវបានអ្នកសិក្សាស្រាវជ្រាវកំណត់ថាជាព្រលឹងជឿនលឿន ដែលយើងបានរក្សាទុកតាំងពីយូរយារណាស់មកហើយ។

បើយោងទៅតាមរយៈជំនឿ ទំនៀមទម្លាប់ប្រពៃណីល្អៗរបស់ខ្មែរ មាតាធិបតេយ្យមានតម្លៃសំខាន់សម្រាប់ស្ត្រីខ្មែរពីរយ៉ាង គឺ ស្ត្រីជាធំ និងស្ត្រីជាមង្គល។[១២] ព្រលឹងខ្មែរចម្បងគេបិតនៅត្រង់ខ្មែរគោរពរបបគ្រប់គ្រងមួយបែបគឺ មាតាធិតេយ្យ ដែលជារបបឱ្យតម្លៃទៅលើស្រីក្នុងការដឹកនាំគ្រួសារក្តី សង្គមខ្មែរទាំងមូលក្តី ចាប់តាំងពីសម័យស្តេចស្រីសោយរាជ្យនៅប្រទេសខ្មែរនៅសម័យហ្វូណន ព្រះនាម សោមា ឬនាងនាគ នៅមុនការទទួលឥទ្ធិពលរបស់ព្រះអង្គមួយអង្គគឺព្រះបាទ កៅណ្ឌិន្យ ឬ ហ៊ុនទៀន ឬ ព្រះថោង ទៅទៀត។ កៅណ្ឌិន្យ នេះទៀតសោតក្នុងពិធីអភិសេកជាមួយនាងសោមា ក៏បានគោរពប្រពៃណីមាតាធិបតេយ្យនេះដែរ ដូចជាការតោងស្បៃដើរតាមក្រោយព្រះនាងសោមា ។

ខ្មែរយើងទម្លាប់ហៅថា"ព្រះថោងតោងស្បៃនាងនាគ" ដើម្បីជាការរំឭកដល់ព្រលឹងខ្មែរសម័យនោះ ចំណែកឯសព្វថ្ងៃនេះ ពិធីរៀបអភិសេក ឬរៀបការក៏តម្រូវឱ្យមានពិធីនេះដែរ។ ក្នុងសង្គមមាតាធិបតេយ្យស្ត្រី ជានិមិត្តរូបនៃវប្បធម៌ជាតិសាសន៍ សិរីសួស្តី សុភមង្គល កិត្តិយស សេចក្តីថ្លៃថ្នូរ ស្អាតស្អំ សោភ័ណភាព ភាពសប្បាយរីករាយ ភាពទន់ភ្លន់ ប្រកបដោយបញ្ញាញាណ ឈ្លាសវៃ ឧត្តុង្គឧត្តម និងសង្គមភាពរបស់គ្រួសារតាំងពីកំណើតមកម្ល៉េះ។[១៣]

ស្រីឬស្ត្រី គឺជាមនុស្សដែលមានសារៈសំខាន់ណាស់ចំពោះប្រទេសជាតិ ព្រោះស្ត្រីគឺជាមនុស្សដែលជួយបម្រើការងារសព្វគ្រប់សារពើ ទាំងការងារសង្គម និងការងារនៅ

[១២]ក្រសួងអប់រំ យុវជន និងកីឡា **សិក្សាសង្គម ថ្នាក់ទី ១០** គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ ឆ្នាំ២០១៦ ទំព័រ ២៣៩។

[១៣] សមាគមបុគ្គលិកសិក្សាខ្មែរ **ទស្សនាវដ្តីគ្រូបង្រៀន លេខ ៣២** ឆ្នាំ២០០៧ ទំព័រ៤៤។

ក្នុងគ្រួសារ នៅគ្រប់ទីកន្លែង គ្រប់ច្រកល្ហក ស្ត្រីបានស្វះស្វែងតស៊ូដោយសេចក្តីអំណត់អត់ធន់សព្វគ្រប់បែបយ៉ាងទាំងអស់ ស្ត្រីមិនត្រឹមតែជាមនុស្សមានសម្ផស្សស្រស់ស្អាត ល្អផូរផង់ប៉ុណ្ណោះទេ ថែមទាំងមានអត្តចរិតសុភាពរាបសារ ទន់ភ្លន់ ស្លូតបូត និងឧស្សាហ៍ព្យាយាមថែមទៀតផង។ ស្ត្រីគឺជាភរិយារបស់បុរស ហើយក៏ជាអ្នកដែលមើលថែរក្សាកូន និងផ្គត់ផ្គង់ក្នុងគ្រួសារ ដើម្បីធ្វើឱ្យគ្រួសារមានសុភមង្គលថែមទៀតផង។ បច្ចុប្បន្នសង្គមខ្មែរច្រើនប្រើពាក្យ "ស្រី" សំដៅលើមនុស្សយុវវ័យ ឬវ័យកណ្តាល ឬអ្នកនៅលីវ ខណៈពាក្យ "ស្ត្រី" ប្រើសំដៅលើអ្នកមានវ័យចាស់។ យ៉ាងណាក៏ដោយ គ្មានការកំណត់ថា អាយុប៉ុន្មាន ត្រូវប្រើពាក្យ ស្ត្រី ឬ ស្រីនោះទេ។ ប៉ុន្តែមជ្ឈដ្ឋានខ្លះ គេយល់ថា ពាក្យ "ស្រី" គឺជាពាក្យមិនសូវល្អឡើយ។ គេតែងច្រើនប្រើពាក្យនេះដោយភ្ជាប់ជាមួយមុខរបរ ឬសកម្មភាពមិនសមរម្យដែលសង្គមមិនសូវឱ្យតម្លៃ។ ឧទាហរណ៍៖ ស្រីបា ស្រីខារ៉ាអូខេ ស្រីខូច...ដោយគេកម្រឃើញប្រើពាក្យថា ស្ត្រីបា ស្ត្រីខារ៉ាអូខេ ស្ត្រីល្បែង...។ មួយវិញទៀត សង្គមខ្មែរក៏និយមប្រើពាក្យ "ស្រី" នេះ ដោយសំដៅលើគូកំណាន់ចិត្តរបស់បុរសដែលមានភរិយារួច ឬនៅលីវ។ ឧទាហរណ៍៖ មានស្រីមានទៅ កុំឱ្យតែប្រពន្ធដឹង ឬម្នាក់ហ្នឹងមានស្រីច្រើនណាស់។

## ១.៣- តំណាលកថាប្រជាប្រិយ

តំណាលកថាប្រជាប្រិយ ដែលជាប្រភេទមួយនៃអក្សរសិល្ប៍ប្រជាប្រិយ។

អក្សរសិល្ប៍ប្រជាប្រិយ គឺជាសញ្ញាណមួយដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងសម្បូរទៅដោយភាពរីកចម្រើនលើផ្នែកសតិអារម្មណ៍ មនោសញ្ចេតនាដែលទទួលបាននូវបណ្តាបទពិសោធន៍ ប្រកបទៅដោយចក្ខុ វិស័យល្អ មានភាពច្នៃប្រឌិតដ៏ប៉ិនប្រសប់ និងមានសមត្ថភាពឥតគណនា បានធ្វើឱ្យស្នាដៃប្រជាប្រិយក្លាយទៅជា "ពហុវប្បធម៌ជាតិ" នៃជាតិខ្មែររបស់យើង។[១៤] សាស្ត្រាចារ្យ ពៅ សាមី បានឱ្យនិយមន័យអក្សរសិល្ប៍ប្រជាប្រិយថា បានដល់នូវអត្ថបទអក្សរសិល្ប៍ទាំងឡាយ ដែលកើតចេញពីប្រជាជន ដើម្បីបម្រើផលប្រយោជន៍ខាងស្មារតី"និពន្ធ និងអប់រំផង" ចំពោះប្រជាជន។ អក្សរសិល្ប៍ប្រជាប្រិយខ្មែរនេះ ត្រូវបានប្រជាជននិយមចូលចិត្ត និងមានការរិះគន់

[១៤] ស៊ុំ ឈុំឡុង **ទស្សនទានអប់រំសង្គមតាមរយៈតំណាលកថានៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ(និក្ខេបបទថ្នាក់បណ្ឌិត)** ភ្នំពេញ ឆ្នាំ២០១១ ទំព័រ១២។

ចំពោះរបបសង្គម ជាពិសេសវណ្ណៈខ្លាំងពូកែដែលតែងតែជិះជាន់ សង្កត់សង្កិនទៅលើវណ្ណៈទន់ខ្សោយ។ អក្សរសិល្ប៍ប្រភេទនេះលេចចេញឡើងនូវគ្រប់សម័យកាលដែលមានទម្រង់ជារឿងព្រេងនិទាន រឿងល្បើកនិងរឿងឧបទេសផ្សេងៗ។ [១៥]

ដូច្នេះយើងអាចឱ្យនិយមន័យជារួមថា អក្សរសិល្ប៍ប្រជាប្រិយ ជាសិល្បៈប្រពៃណី ជាសិល្ប៍វោហារសាស្ត្រ ផ្សារភ្ជាប់គ្នាជាមួយនឹងការផ្សព្វផ្សាយរបស់មនុស្ស ជាអក្សរសាស្ត្រចំណេះដឹង ជាវចនានុក្រមវិទ្យានិងជាការអនុវត្តដែលត្រូវបានចែកចាយយ៉ាងទូលំទូលាយ ឆ្លងកាត់ពីមាត់មួយទៅមាត់មួយ ពីសម័យកាលមួយទៅសម័យកាលមួយ ហើយមានការប្រែប្រួលរហូតដល់រកម្ចាស់ដើមពុំឃើញ ពោលគឺត្រូវបានប្រជារាស្ត្រសាមញ្ញ ជាអ្នកបង្កើតឡើង ដោយបង្ហាញពីភាពរីកចម្រើននៃប្រវត្តិសាស្ត្រសង្គម ផ្នែកកបញ្ញាស្មារតី សតិអារម្មណ៍ និងមនោសញ្ចេតនាដ៏ជ្រាលជ្រៅ។

ចំណែកតំណាលកថា គឺជារឿងរ៉ាវទាំងឡាយដែលលេចធ្លោចេញពីការនិទានឬតំណាលតៗគ្នានៃមនុស្សដែលរស់នៅក្នុងសហគមន៍ ដោយគ្មានឈ្មោះអ្នកនិពន្ធ គ្មានកាលបរិច្ឆេទច្បាស់លាស់។ តំណាលកថាទាំងនោះត្រូវបានប្រជាជននិយមពេញចិត្តហើយបង្កើតបានជាការផ្សព្វផ្សាយនិយាយតគ្នាពីមាត់មួយទៅ មាត់មួយ ពីភូមិមួយទៅភូមិមួយ ពីតំបន់មួយទៅតំបន់មួយ។ តំណាលកថាប្រជាប្រិយមានខ្លឹមសារឆ្លុះបញ្ចាំងពីជីវភាពរស់នៅរបស់ប្រជាជនគ្រប់ជ្រុងជ្រោយ ក្នុងសម័យប្រវត្តិសាស្ត្រខុសៗគ្នាគិតតាំងពីសម័យកាលដែលយើងមិនទាន់មានឯកសារជាក់លាក់ម៉្លេះ។ បុព្វបុរសខ្មែរបានផ្តាំផ្ញើតាមរយៈរឿងនិទានប្រជាប្រិយនូវមនោសញ្ចេតនា សេចក្តីប៉ងប្រាថ្នា ទស្សនៈពីពិភព និងជីវភាពនៃសង្គមមនុស្សនាសម័យនោះ។

តំណាលកថាប្រជាប្រិយ ទោះបីជាមានជាតុមិនសូវជាក់ស្តែង ប៉ុន្តែក៏នៅមានទម្រង់ជាមួយប្រវត្តិសាស្ត្រដែរ គ្រាន់តែតិចឬច្រើន។ មានពេលខ្លះតួអង្គក្នុងរឿងជាតួអង្គប្រវត្តិសាស្ត្រដូចជា ព្រះថោង ជ័យវរ្ម័នទី២ តាត្រសក់ផ្អែម...សុទ្ធជាតួអង្គដែលមានពិតក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ចំណុចសំខាន់មួយទៀត គឺតំណាលកថាប្រជាប្រិយ ជាពិសេសព្រេងកថា ច្រើនលើកឡើងពីទឹកចិត្ត ស្នេហា

[១៥] ពៅ សាមី **មូលដ្ឋានទ្រឹស្តីអក្សរសិល្ប៍ និងសិល្បវិទ្យា ភាគ៣** គ្រឹះស្ថានបោះពុម្ពសុភមង្គល ឆ្នាំ ២០១២ ទំព័រ១១៨។

ជាតិ ពីដើមកំណើតប្រជាជនក្នុងការប្រយុទ្ធប្រឆាំងជាមួយបរទេសឈ្លានពាន ដើម្បីការពារឯករាជ្យភាពរបស់ប្រជាជន។

តាមរយៈតំណាលកថាប្រជាប្រិយ យើងឃើញថា ប្រវត្តិសាស្ត្រសង្គមមនុស្សជាប្រវត្តិនៃការតស៊ូជានិច្ចកាល ក្នុងនោះមានការប្រយុទ្ធប្រឆាំងនឹងធម្មជាតិ និងវណ្ណៈជិះជាន់ក្នុងសង្គមមានវណ្ណៈ។ ស្មារតីវាយប្រហារវណ្ណៈជិះជាន់របស់ប្រជាជនបានអនុវត្តតាមរយៈរឿងមួយចំនួនដូចជារឿងធនញ្ជ័យ រឿងអាឡេវ រឿងមាយើង... ដែលក្នុងនោះស្ដេច មន្ត្រី និង ភ្នាក់ងារតូចតាច មានចរិតសាហាវយង់ឃ្នង ពុករលួយ ក្បត់កុហក ត្រូវបានប្រជាពលរដ្ឋលើកយកមកបញ្ចូលក្នុងតំណាលកថាប្រជាប្រិយ ដោយបង្កើតឱ្យមានតួអង្គតំណាងជនប្រភេទនោះ ដើម្បីធ្វើការរិះគន់ បន្ទុះបង្អាប់ និងសើចចំអក ក្នុងគោលបំណងកែប្រែ ដូចជារឿងសុភាសេក និងរឿងភេពីរ។ ចំណែកឯស្ដេច មន្ត្រីណាដែលឈ្លាសវៃ ស្លូតបូតសុចរិតទៀងត្រង់ ត្រូវបានប្រជាជនស្រឡាញ់ស្ញើចសរសើរ ហើយរស់នៅជានិច្ចក្នុងស្រទាប់មហាជន។ បើតាមលោក ហ្គ័រគី បានមានប្រសាសន៍អំពីអត្ថន័យតំណាលកថាប្រជាប្រិយថា គ្មានអ្វីក្រៅពីទឹកចិត្តដែលទន្ទឹងយ៉ាងខ្លាំងរបស់ពលករសម័យដើម ដែលមានបំណងចង់ឱ្យការងារកាន់តែធូរស្រាល ផលិតកម្មកាន់តែកើនឡើង និងចង់ប្រឆាំងនឹងសត្រូវជើងពីរ និងជើងបួនបានលទ្ធផលកាន់តែប្រសើរឡើង។[១៦]

នៅក្នុងតំណាលកថាខ្លះទៀត បានលើកយកតួអង្គមនុស្សមកសម្ដែងតែម្ដង ហើយដំណោះស្រាយ គេតែងតែប្រើកម្លាំងកាយ កម្លាំងប្រាជ្ញា និងកលល្បិចរបស់មនុស្សមកធ្វើជាមធ្យោបាយ ដូចជារឿងបុរសចាក់ស្មុគ មាយាស្រី សម្លាញ់ពីរនាក់នៅផ្ទះជិតគ្នា រឿងអាឡេវ រឿងសម្លាញ់ពីរនាក់បាចទឹកសមុទ្រ ជាដើម។

## ២. ឧត្តមភាពស្ត្រីតាមរយៈតំណាលកថាមួយចំនួន

ក្នុងការបកស្រាយឧត្តមភាពស្ត្រីតាមរយៈតំណាលកថា បានលើកឡើងនូវបញ្ហាសង្គមមនុស្សជាច្រើន ដែលប្រកបដោយអត្ថន័យនិងមានតម្លៃសម្រាប់មនុស្សជាតិជំនាន់ក្រោយ។ ការអប់រំក្នុងរឿងភាគច្រើនទាក់ទងនឹងសកម្មភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ជាពិសេសអ្នកនិពន្ធបានលើកឡើងនូវឧត្តមភាពស្ត្រីក្នុងសង្គម។ រឿងមួយ

---

[១៦] សន្ទរកថាអានរបស់លោក **ហ្គ័រគី** នៅក្នុងសន្និបាតអ្នកនិពន្ធសូវៀត ឆ្នាំ១៩៣៤។

ចំនួនបានបង្ហាញនូវការអប់រំមនុស្សឱ្យមានសច្ចៈ ខន្តី កតញ្ញូចំពោះមនុស្សនៅជុំវិញខ្លួន មានការអប់រំសមាជិកគ្រួសារឱ្យមានភាពស្មោះត្រង់នឹងគ្នា ជាពិសេស គឺប្តីនិងប្រពន្ធត្រូវចេះស្រឡាញ់ស្មោះស្ម័គ្រនឹងគ្នា កុំលួចមានសហាយ ដោយការលោភលន់នឹងតណ្ហា។ ការអប់រំកូនឱ្យមានភាពស្មោះត្រង់ចំពោះមាតាបិតា ចេះគោរពប្រពៃ ចេះដឹងគុណមាតាបិតា ចេះថែរក្សាពូជពង្សវង្សត្រកូលឱ្យបានល្អ ស្អាតស្អំ មានកិត្តិយសក្នុងសង្គមឱ្យថ្លៃថ្នូរល្អប្រពៃ។ ការអប់រំឱ្យចេះជួយសង្គ្រោះគ្នានៅគ្រាមានអាសន្ន និងបន្តរស់នៅជួបជុំគ្នាប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជាពិសេសគឺបានបង្ហាញពីការអប់រំមនុស្សនូវភាពលោភលន់ហួសប្រមាណ ដែលជាបញ្ហាគ្រោះថ្នាក់មកដល់ខ្លួនវិញនៅពេលក្រោយ ដោយបង្ហាញពីការចូលរួមក្នុងសង្គមពីសកម្មភាពរបស់ស្ត្រីប្រកបដោយការវាងវៃ ការសហការ ការប្រកួតប្រជែងគ្នា និងការជំរុញសេដ្ឋកិច្ចក្នុងការកសាងសង្គមជាតិឱ្យកាន់តែមានការអភិវឌ្ឍ។

## ២.១- ឧត្តមភាពស្ត្រីតាមរយៈការបំពេញតួនាទីនៅក្នុងគ្រួសារ

### ២.១.១- ឧត្តមភាពស្ត្រីជាកូន

កូន គឺមានន័យថា ជាមនុស្ស ឬសត្វ ដែលកើតអំពីមាតាបិតា មេបា : កូនប្រុស, កូនស្រី, កូនឈ្មោល, កូនញី។ សេចក្តីស្រឡាញ់រវាងឪពុកម្តាយនឹងកូន គឺជាសេចក្តីស្រឡាញ់ដ៏ស្មោះ រកអ្វីមកប្រៀបផ្ទឹមពុំបាន ព្រោះសេចក្តីស្រឡាញ់មួយនេះវាធំធេងណាស់។ ឪពុកម្តាយចង់ឃើញកូនៗរបស់ខ្លួនបានសេចក្តីសុខ ចម្រុងចម្រើន មានសុភមង្គល ហើយក៏មិនចង់បានអ្វីជាការតបស្នងត្រឡប់ពីកូនៗមកវិញក្រៅពីការដែលឃើញកូនជាកូនប្រកបដោយកតញ្ញូ មានគុណធម៌ សីលធម៌ល្អនោះឡើយ។ ដូច្នេះកូនៗទាំងអស់គប្បីត្រូវតែរក្សា និងគោរពដឹងគុណលោកអ្នកមានគុណឱ្យបានសមស្រប មិនថាលោកធ្លាប់បានធ្វើអ្វីខុសឆ្គងបន្តិចបន្តួច ឬយ៉ាងណានោះទេ យើងជាកូនល្អ ត្រូវតែចេះតបស្នងសងគុណលោក មិនបំផ្លាញកិត្តិយស មិនបណ្តោយខ្លួនឱ្យធ្លាក់ក្នុងសេចក្តីល្ងង់ខ្លៅ ដែលនោះហើយជាសេចក្តីសុខដែលអ្នកមានគុណយើងចង់បាន និងរីករាយទទួលយកនូវការតបគុណដ៏វិសេសវិសាលនោះ។ តួយ៉ាងនៅក្នុងរឿងដើមរលួសមាស (រឿងទី២៤នៃប្រជុំរឿង

ព្រេងខ្មែរ ភាគទី៧) តួអង្គនាងកុមារិកា មានឪពុកម្ដាយចុង រស់នៅមិនជួបជុំគ្នាជាមួយម្ដាយដើមក៏ដោយ នាងនៅតែគោរពដឹងគុណចំពោះលោកឪពុករបស់នាងមិនដែលជំទាស់នោះឡើយ ថ្វីត្បិតតែម្ដាយបង្កើតនាងកើតជាសត្វត្រី កើតជាដើមត្រប់ ក៏នាងនៅតែគោរពស្រឡាញ់ និងតាមថែរក្សាលោកអ្នកមានគុណជាដរាប។ មាតាបិតានាងពេញចិត្តព្រមទទួលយកការមើលថែទាំរបស់នាង មិនដែលប្រាថ្នាថាចង់បានកូនណាម្នាក់ត្រូវតែយកមាសប្រាក់ កែវកងដើម្បីមកតបស្នងគុណលោកវិញនោះទេ គឺមានតែសេចក្ដីនឹករឭក ឃើញកូនមានសេចក្ដីសុខក៏លោកសប្បាយចិត្តដែរ។

## ២.១.២- ឧត្តមភាពស្ត្រីជាម្ដាយ

ពាក្យថា"ម្ដាយ" មានន័យថា មាតា ម៉ែ ជាពាក្យដែលងាយហៅ ប៉ុន្តែមានអត្ថន័យធំធេងជ្រាលជ្រៅមិនអាចកាត់ថ្លៃបាន។ ម្ដាយជាស្ត្រីម្នាក់ដែលបានលះបង់សាច់ស្រស់ឈាមស្រស់ ពលីគ្រប់បែបយ៉ាងដើម្បីកូនគ្រប់ៗគ្នា។ តួនាទីយ៉ាងសំខាន់បំផុតរបស់ស្ត្រីដែលមិនអាចមានអ្វីមកប្រៀបផ្ទឹមនិងកាត់ថ្លៃបាននោះគឺ តួនាទីជាអ្នកផ្ដល់កំណើតដល់បុត្រធីតា។ មិនត្រឹមតែជាអ្នកផ្ដល់កំណើតប៉ុណ្ណោះទេ តែតួនាទីជាម្ដាយ គឺមានភារកិច្ចធំធេងណាស់ក្នុងការចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ អប់រំទូន្មាន និងធ្វើខ្លួនយ៉ាងណាឱ្យក្លាយជាគំរូល្អដល់បុត្រធីតាគ្រប់ៗរូប ដើម្បីឱ្យពួកគេក្លាយទៅជាកូនល្អ ពលរដ្ឋល្អនៅក្នុងសង្គម។ ម្ដាយ ឬមាតា ឬម៉ែ គឺជាបុគ្គលសំខាន់ និងមានគុណតម្លៃខ្លាំងណាស់សម្រាប់បុត្រធីតា។ ម្ដាយជាអ្នកដែលនៅជិតស្និទ្ធ នៅជិតកូន និងមើលថែទាំកូនជាច្រើនជាងឪពុក។ ម្ដាយជាបុគ្គលដែលតែងតែខ្វាយខ្វល់ពីសុខទុក្ខ អនាគតរបស់កូនៗគ្រប់ពេលវេលា និងជាអ្នកចាំជួយចង្អុលបង្ហាញផ្លូវដល់កូនគ្រប់ៗរូបឱ្យដើរក្នុងផ្លូវត្រូវ ដើម្បីកសាងអនាគតរបស់ពួកគេទៅថ្ងៃមុខ។

តាមរយៈស្នាដៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ រឿងស្ត្រីពិត ម្ដាយពិត ឪពុកពិត រឿងដើមរលួសមាស បានបង្ហាញពីតួនាទីរបស់ស្ត្រី ក្នុងនាមជាម្ដាយមួយរូបដែលហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីអនាគតកូន។ រឿងស្ត្រីពិត ម្ដាយពិត ឪពុកពិត បានបង្ហាញពីស្ត្រីដែលជាម្ដាយ ដែលជាស្ត្រីពោរពេញទៅដោយគំនិត និងល្បិចកល ដើម្បីធ្វើយ៉ាងណារើសបានកូនប្រសាដែលសក្តិសមទៅនឹងកូនស្រី។ គាត់តែងព្រួយបារម្ភពីអនាគតរបស់កូនស្រី ជាពិសេសនៅពេលរៀបចំឱ្យ

កូនមានគូស្រករ គាត់មានគំនិតខ្ពស់ក្នុងការដាក់បន្ទុកទៅលើបុរសរូបណា ដែលបានចូលមកស្ដីដណ្ដឹងកូនស្រីគាត់។ រាល់ពេល និងគ្រប់មធ្យោបាយ ល្បិចកលដែលប្ដីបានប្រព្រឹត្តិសុទ្ធតែកើតចេញពីគំនិតរបស់គាត់ជាកវិយា គឺជាអ្នកផ្ដល់យោបល់ និងរៀបចំចាត់ចែងគ្រប់ផែនការ ក្នុងគោលបំណងធ្វើយ៉ាងណារើសបានបុរសល្អម្នាក់សម្រាប់កូនស្រីរបស់គាត់។ គាត់បានបំពេញតួនាទីជាម្ដាយបានយ៉ាងល្អសម្រាប់កូនស្រីជាទីស្រឡាញ់របស់គាត់។ ដោយឡែកនៅក្នុងរឿងដើមរលួសមាស ក៏បង្ហាញពីតម្លៃស្ត្រីដែលមាននាទីជាម្ដាយ ដែលជាស្ត្រីចេះគិតគូរពីកូនដែរ គឺតួអង្គនាងកុលកេសី ទោះបីជានាងត្រូវស្លាប់ដោយសារការឈ្នានីសពីនាងប្រពន្ធចុងជាច្រើនលើកច្រើនដងយ៉ាងណា ក៏នាងនៅតែទៅតាមកើតជាសត្វ ជារុក្ខជាតិជាច្រើនដង ដើម្បីតាមថែរក្សាកូន គឺនាងចង់ត្រឹមឃើញតែនាងកុមារិកាជាកូនរស់នៅដោយសេចក្ដីសុខ មិនមានអ្នកធ្វើបាប កូនមានប្ដីល្អ មានអ្នកមើលថែទាំជំនួសនាង ចង់ឱ្យកូនមានប្ដីជាអ្នកមានលក្ខណៈគ្រប់គ្រាន់ដែលធ្វើឱ្យកូននាងរស់នៅសុខស្រួលមិនជួបនូវការលំបាកឡើយ ព្រោះក្នុងសង្គមគេឱ្យតម្លៃលើចំណេះវិជ្ជាលើការមានសុខភាពល្អ ការមានកិត្តិយសថ្លៃថ្នូរ ទើបមាតាបិតានៃកូនស្រីពេញចិត្តទទួលយកមកធ្វើជាកូនប្រសា ពោលគឺនាងបានចិញ្ចឹមបីបាច់កូនស្រីបានយ៉ាងល្អប្រពៃសក្ដិសមជាកុលស្ត្រីដែលបុរសទាំងឡាយតែងប្រាថ្នាចង់បានជាគូអនាគត។

យ៉ាងណាមិញ តួអង្គម្ដាយចុង នាងកាឡី ក៏ជាម្ដាយម្នាក់ដែលតែងតែគិតគូរពីអនាគតកូនស្រីរបស់ខ្លួនដែរ គឺនាងកាឡកណ្ណី(ចន្ទី) និងកាឡីនីយា(ចន្ទី)។ ការសម្រេចចិត្តរបស់នាងកាឡី ជាការសម្រេចចិត្តប្រកបដោយគតិ ព្រោះចង់ឱ្យកូនបានស្វាមីដែលជាអ្នកមានទ្រព្យសម្បត្តិ ក្នុងនោះផងដែររឿងនេះក៏បានបង្ហាញពីតួអង្គស្ត្រី ជាម្ដាយរបស់ចន្ទី និងចាន្ទី គឺជាម្ដាយដែលមានចិត្តអាក្រក់ ប៉ុន្តែនាងបានធ្វើគ្រប់យ៉ាងគឺដើម្បីកូនៗរបស់គាត់មានបាន គ្រាន់តែគាត់ធ្វើដោយមិនសមហេតុផល ទើបទទួលបានលទ្ធផលមិនសមតាមបំណងនោះ។ ដូចគ្នាដែរបើយើងវិភាគឱ្យមែនទែនទៅ គឺគាត់លះបង់ធំធេងណាស់សម្រាប់កូនៗ។ ទោះបីកូនស្រីនាងចន្ទី រឹងទទឹងមិនស្ដាប់បង្គាប់ប្រឆាំងនឹងគាត់នៅពេលដែលគាត់បានលើកនាងឱ្យទៅជាមហេសីស្ដេចដែលមានទ្រព្យសម្បត្តិ ក៏នាងនៅតែមិនដាច់ចិត្តពីកូនស្រី មានន័យថា ម្ដាយនៅតែមិនដាច់

អាល័យពីកូន នៅតែបារម្ភពីសុខទុក្ខកូនស្រី ខ្លាចកូនជួបប្រទះការលំបាក ទើបនាងសុខចិត្តលួចប្រមូលទ្រព្យសម្បត្តិ និងរបស់របរមានតម្លៃជាច្រើនដាក់ឱ្យកូនស្រីយកទៅជាមួយ ព្រោះខ្លាចកូនខ្វះខាត ក្រខ្សត់ ទោះកូនចេញទៅឆ្ងាយក៏នាងនៅតែគិតបារម្ភគ្រប់ពេលគ្រប់វេលាពីសុខទុក្ខកូន គ្មានពេលរសាយឡើយ នេះហើយជាទឹកចិត្ត និងជាតួនាទីស្ត្រីជាម្ដាយ។

សរុបមកតាមរយៈស្នាដៃអក្សរសិល្ប៍ប្រជាប្រិយខ្មែរ គឺពិតជាបានរំលេចឱ្យយើងមើលឃើញពីគុណតម្លៃរបស់ស្ត្រីដែលមាននាមជាជាម្ដាយ ជាអ្នកមានគុណដ៏លើសលប់សម្រាប់កូនៗគ្រប់ៗគ្នា មិនអាចនឹងរកអ្វីមកប្រៀបផ្ទឹមឬជំនួសបានឡើយ។

### ២.១.៣- ឧត្តមភាពស្ត្រី ជាភរិយា

ភរិយា ស្ត្រីដែលបានរៀបការជាមួយបុរសណាម្នាក់ ហើយបុរសជាស្វាមីត្រូវចិញ្ចឹម មើលថែ ពោលគឺជាស្ត្រីមួយរូបដែលជាដៃគូជីវិតរបស់បុរស ហើយភរិយាក៏ជាអ្នកមើលថែ ជួយជំរុញលើកទឹកចិត្តស្វាមី និងជាដៃគូពិភាក្សា ជាទីប្រឹក្សារបស់ស្វាមីគ្រប់រឿងរ៉ាវទាំងអស់ ពោលគឺរួមសុខ រួមទុក្ខជាមួយស្វាមី ដូចពាក្យគេថា បុរសជោគជ័យ ឬបរាជ័យ ក៏ជាការរួមចំណែករបស់ស្ត្រីជាភរិយាផងដែរ។ ភរិយាមាននាទីគោរពប្រណិប័តន៍ចំពោះស្វាមី និងចាត់ចែងរាល់កិច្ចការទាំងឡាយក្នុងផ្ទះ ទាំងអាហារ សម្លៀកបំពាក់ សម្ភារៈប្រើប្រាស់របស់ស្វាមី។

តាមរយៈតំណាលកថាមួយចំនួនដែលជាអក្សរសិល្ប៍ប្រជាប្រិយខ្មែរដូចជារឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ រឿងគង់ហ៊ាន និងរឿងមាយើង គឺសុទ្ធតែបានលាតត្រដាងពីតួអង្គស្ត្រីគ្រប់លក្ខណ៍ដែលជាភរិយារបស់បុរសៗ។ ក្នុងរឿង គង់ហ៊ាន នាងគំ នាងអាំ ដែលភរិយារបស់គង់ហ៊ាន សុទ្ធតែជាភរិយាដែលនាំមកនូវសេចក្ដីចម្រើនរុងរឿងដល់គ្រួសារ គឺនាងជួយយោងបុរសជាស្វាមី ដូចសុភាសិតខ្មែរដែលលើកឡើងថា សំណាបយោងដី ស្រីយោងប្រុស។ ក្នុងនោះរឿងបុរសកម្ជិលមានប្រពន្ធគ្រប់លក្ខណ៍ បានបង្ហាញពីភរិយាមានលក្ខណៈល្អប្រពៃទន់ភ្លន់ ស្មោះស្ម័គ្រចំពោះស្វាមី ទោះស្វាមីជាមនុស្សខ្ជិលច្រអូសក៏នាងនៅតែស្រឡាញ់ស្មោះត្រង់ចំពោះប្ដី គ្មានចិត្តវៀចវេរឡើយ។ នាងជាភរិយាដែលប្រកបដោយលក្ខណៈសម្បត្តិ និងនាំតែភាពចម្រើនរុងរឿងដល់ប្ដី ព្រមទាំងជាភរិយាដែលបំពេញតួនាទីបានយ៉ាងល្អចំពោះស្វាមីនាង។ ដូចគ្នានេះដែរស្ត្រីដែលជាភរិយារបស់

គង់ហ៊ាន ឯណោះវិញ ក៏ជាភរិយាដែលមានភាពឈ្លាសវៃ ប៉ិនប្រសប់ ស្មោះត្រង់ មោះមុត និងក្លាហាន គឺនាងៗហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីបានរស់នៅជាមួយបុរសដែលនាងស្រឡាញ់ រួមរស់ជាប្ដីប្រពន្ធដោយមិនខ្លាចរអា ហ៊ានតស៊ូប្រយុទ្ធប្រឆាំងជាមួយសត្រូវក្នុងការវាយលុកជាមួយសត្រូវដែលឈ្លានពាន និងពុះពារការលំបាកមិនរាថយនោះឡើយ។ នាងបានបំពេញតួនាទីនាងជាភរិយាដោយជួយមើលថែរក្សាប្ដី គិតគូរពីសុខទុក្ខរបស់ប្ដីគ្រប់ពេលវេលា ចង់ឱ្យគ្រួសារមានភាពរីកចម្រើនទៅមុខ ជួយជ្រោមជ្រែងលើកទឹកចិត្តប្ដី គិតគូររឿងរ៉ាវដែលស្ដេចដាក់បញ្ញាឱ្យប្ដីធ្វើគ្រប់កិច្ចការទាំងអស់ រហូតទទួលបានជោគជ័យ។

នៅក្នុងរឿងមាយើង វិញនោះ ក៏បានបង្ហាញពីតួអង្គស្ត្រី ជាភរិយាក្រោយរបស់ចៅមាណពដែលជាស្ត្រីប្រកបទៅដោយលក្ខណៈសម្បត្តិសមសួនជាបញ្ចពិធកល្យាណីស្រីគ្រប់លក្ខណ៍ ល្អទាំងរូប ល្អទាំងចិត្ត ដែលនាងចេះសព្វកិច្ចការជួយស្វាមីបានគ្រប់ការកិច្ច។ នាងបានបំពេញតួនាទីជាភរិយាដែលចេះទំនុកបម្រុង ជួយលើកស្ទួយប្ដីដែលជាបុរសកម្សត់ប្ដីដែលខ្វះនូវប្រាជ្ញាឱ្យក្លាយទៅជាអ្នកមានទ្រព្យ និងកិត្តិយសបាន។

ជារួមមក តួនាទីស្ត្រីជាភរិយាពិតជាមានសារៈសំខាន់ សម្រាប់ស្វាមីដែលមិនអាចខ្វះដៃគូជីវិតនេះបានឡើយ ហើយតាមរយៈតំណាលកថាប្រជាប្រិយខ្មែរយើងពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីតួនាទីរបស់ស្ត្រីដែលសំខាន់នោះ គឺតួនាទីជាភរិយាល្អ ជាភរិយាដែលចេះជួយលើកកិត្តិយសប្ដី ចេះជួយការពារប្ដី ចេះរកមធ្យោបាយដោះស្រាយសម្រាប់ភាពជោគជ័យរបស់គ្រួសារ និងសេចក្ដីសុខសុភមង្គលនៅក្នុងគ្រួសារ។

### ២.២- ឧត្តមភាពស្ត្រីជាអ្នកដឹកនាំ និងជាមេគ្រួសារ

ដើម្បីឱ្យប្រទេសនីមួយៗ ស្ថាប័នឬក្រុមហ៊ុននីមួយៗ ក៏ដូចជាក្រុមគ្រួសារនីមួយៗ មានការគ្រប់គ្រងល្អ មានដំណើរការប្រព្រឹត្តិទៅដោយរលូន និងមានការអភិវឌ្ឍនោះ ចាំបាច់ត្រូវតែមានអ្នកដឹកនាំដែលល្អនិងខ្លាំងពូកែ ដើម្បីដឹកនាំនិងរិះរកមធ្យោបាយដឹកនាំទៅរកភាពជោគជ័យ។ ការដឹកនាំមានភាពល្អប្រសើរ ចាំបាច់ត្រូវមានអ្នកដឹកនាំល្អដែលមានសមត្ថភាពដែលអាចដឹកនាំបាន។ យ៉ាងណាមិញ ស្ត្រីក៏បានដើរតួនាទីយ៉ាងសំខាន់ទាំងនៅក្នុងសង្គមគ្រួសារនិងក្នុង

សង្គមជាតិ ពោលគឺទាំងក្នុងសង្គមគ្រួសារ
និងសង្គមជាតិមិនអាចអវត្តមានស្ត្រីបានឡើ
យ។ ស្ត្រីជាកម្លាំងចលករដែលជំរុញឱ្យ
សង្គមគ្រួសារនិងសង្គមជាតិមានការរីក
ចម្រើនឈានទៅមុខ ក៏ដោយសារស្ត្រីមាន
លក្ខណៈពិសេសម្យ៉ាង នោះគឺមានភាពជា
អ្នកដឹកនាំ។ ស្ត្រីមានគំនិតផ្តួចផ្តើមចាត់ចែង
រៀបចំកិច្ចការតូចធំ ទាំងក្នុងផ្ទះនិងក្រៅផ្ទះ
រហូតដល់ពេលខ្លះ ភាពដឹកនាំរបស់ស្ត្រីក្នុង
គ្រួសារត្រូវបានចារនៅក្នុងផ្នត់គំនិតប្រជា
ជនទូទៅ ដូចជាពំនោលលើកឡើងថា ស្ត្រី
ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិនិង គ្រួសារ។
ទោះបីជាស្ត្រីមានកាយសម្បទាមិនរឹងមាំនិង
ខ្លាំងក្លាដូចបុរសក៏ពិតមែន តែស្ត្រីក៏មាន
គំនិតឈ្លាសវៃគួបផ្សំនឹងការអត់ធ្មត់ខ្ពស់
មានភាពហានក្លា ដែលជាហេតុធ្វើឱ្យស្ត្រី
អាចដឹកនាំគ្រួសារ និងសង្គមជាតិឱ្យបានរីក
ចម្រើនរុងរឿង មានសុខសុភមង្គល។

តាមរយៈរឿងមាយើង និងរឿងប្រវត្តិ
ឃុំវាលជួប ដែលជាតំណាលកថាប្រជាប្រិយ
នៃប្រជាជាតិខ្មែរយើង ក៏បានបង្ហាញពីតួអង្គ
ស្ត្រីដែលមានគំនិតជាអ្នកដឹកនាំ មានភាព
ស្វាហាប់ ក្លាហាន មោះមុត ជំនះនូវគ្រប់
បញ្ហារហូតសម្រេចបានតាមគោលបំណង។
តួអង្គស្ត្រីក្នុងរឿងទាំងពីរសុទ្ធសឹងតែជា
បុគ្គលមានលក្ខណៈរឹងមាំ បង្ហាញពីភាព
ខ្លាំងក្លាក្នុងការដឹកនាំ ចាត់ចែងកិច្ចការនា
នា។ តួអង្គស្ត្រីក្នុងរឿងប្រវត្តិឃុំវាលជួប ជាតួ
អង្គដែលមានគំនិតជឿនលឿន ដឹកនាំស្ត្រី
ទាំងឡាយឱ្យហ៊ានរើបម្រះចេញពីអ្វីដែល
ខ្លួនគិតថាមិនសមរម្យ ដោយរិះរកគ្រប់
មធ្យោបាយ និងព្យាយាមធ្វើយ៉ាងណា
បង្ហាញពីឧត្តមភាពរបស់ខ្លួនមិនចាញ់បុរស
ឡើយ។ ស្ត្រីជាបុគ្គលដែលមានគំនិតទស្ស
នៈជាអ្នកដឹកនាំ ដែលអាចនាំសង្គមគ្រួសារ
និងសង្គមជាតិបានរីកចម្រើន ព្រមទាំងជា
បុគ្គលដែលគ្រួសារនិងសង្គមមិនអាចខ្វះបា
ន។ បរិបទនៃសង្គមខ្មែរតាំងពីសម័យបុរាណ
កាលមក ព្រលឹងមាតាធិបតេយ្យ ដែលជា
ព្រលឹងមួយដ៏សំខាន់របស់ជនជាតិខ្មែរ បាន
ចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិតខ្មែរ។
ស្ត្រីត្រូវបានគេឱ្យតម្លៃនិងចាត់ទុកជាអ្នក
ដឹកនាំ ជាមេគំនិតក្នុងការគ្រប់គ្រង និង
ចាត់ចែងការងារតូចធំក្នុងគ្រួសារ។ ដោយសារ
តែគេចាត់ទុកស្ត្រីជាធំ ឬជាអ្នកគ្រប់គ្រង
ដឹកនាំនេះហើយ ទើបមានពាក្យថា "មេ" ប្រើ
ក្នុងជីវភាពប្រចាំថ្ងៃដើម្បីសម្គាល់ភាពជាធំ
ឬភាពជាអ្នកគ្រប់គ្រងដឹកនាំ ទោះបីបុគ្គល
នោះជាបុរសក៏ដោយ ដូចជាមេទ័ព មេជាង
មេដំបូល មេដៃ មេឃុំ មេភូមិ...ដែលជាពាក្យ
សម្គាល់ជាប្រមុខដឹកនាំ។ ពាក្យ "មេ" ក៏

សម្រាប់ហៅស្ត្រីនៅក្នុងគ្រួសារផងដែរគឺ "មេផ្ទះ" សំដៅដល់អ្នកគ្រប់គ្រងចាត់ចែងកិច្ចការក្នុងផ្ទះសម្បែង។ ស្ត្រីមិនត្រឹមតែមានតួនាទីក្នុងការគ្រប់គ្រងនៅក្នុងផ្ទះប៉ុណ្ណោះទេ នាពេលបច្ចុប្បន្ន ស្ត្រីក៏ត្រូវបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ និងលើកទឹកចិត្តឱ្យចូលរួមក្នុងការងារដឹកនាំនៅក្នុងសង្គមថែមទៀត។ ក្នុងការប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិជារៀងរាល់ឆ្នាំ ជាទូទៅប្រមុខនៃរាជរដ្ឋាភិបាលបានទទូចស្នើសុំឱ្យគ្រប់ក្រសួងថ្នាក់ដឹកនាំស្ថាប័នត្រូវបន្តបង្កើនលើកស្ទួយ និងបង្កើតឱកាសឱ្យស្ត្រីមានវត្តមានក្នុងតួនាទីជាថ្នាក់ដឹកនាំនៅគ្រប់ កម្រិត។ ក្នុងន័យនេះប្រមុខនៃរាជរដ្ឋាភិបាល យើងលោកចង់ផ្តល់ការលើកទឹកចិត្តដល់ស្ត្រីឱ្យក្លាហានក្នុងការចូលរួមកិច្ចការងារសង្គម ពិសេសគឺតួនាទីជាអ្នកដឹកនាំ ពោលគឺឱ្យយើងមើលឃើញពីយកចិត្តទុកដាក់ និងលើកកម្ពស់ឧត្តមភាពរបស់ស្ត្រីពីសំណាក់ប្រមុខរាជរដ្ឋាភិបាលខ្មែរក៏ដូចជាស្ថាប័នពាក់ព័ន្ធនានានៅក្នុងសង្គម។

ថ្វីត្បិតតែស្ត្រី ជាភេទទន់ខ្សោយ មានកម្លាំងមិនស្មើនឹងបុរស មិនអាចធ្វើការងារដែលប្រើកម្លាំងខ្លាំងដូចបុរសក៏ពិតមែន ប៉ុន្តែនៅក្នុងសង្គមគ្រួសារខ្មែរ ស្ត្រីគឺមានឥទ្ធិពលក្នុងគ្រួសារ មានឥទ្ធិពលលើស្វាមី និងលើកូនចៅ។ ស្ត្រីភាគច្រើនត្រូវបានផ្តល់សិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ចាត់ចែងដឹកនាំ រឿងតូចធំក្នុងគ្រួសារ។ ស្ត្រីគឺជាអ្នកទទួលបន្ទុកអប់រំទូន្មានកូនចៅឱ្យក្លាយជាកូនល្អ ពលរដ្ឋល្អនៅក្នុងសង្គម។ ជាពិសេសនោះគឺស្ត្រីជាមាតាមានកាតព្វកិច្ចយ៉ាងសំខាន់ក្នុងការរៀបចំអនាគតបុត្រធីតា ការគ្រប់គ្រងថែរក្សាលើទ្រព្យសម្បត្តិ លុយកាក់ និងបញ្ហាផ្សេងៗនៅក្នុងគ្រួសារ។ នៅក្នុងការឱ្យតម្លៃចំពោះស្ត្រីទៅតាមរយៈទស្សនៈចាត់ទុកស្ត្រី ជាអធិបតីនៅក្នុងការដឹកនាំ ក៏បានបង្កប់នៅក្នុងវណ្ណកម្មអក្សរសិល្ប៍ខ្មែរជាច្រើន ពិសេសក្នុងប្រភេទអក្សរសិល្ប៍ប្រជាប្រិយខ្មែរ។ ប្រសិនបើយើងអានស្នាដៃរឿងមាយើង ជាប្រភេទពាក្យកាព្យ ក៏បានបង្ហាញឱ្យឃើញពីការប្រកាន់យកនូវការផ្តល់តម្លៃដល់ស្ត្រីជាធំ។ រឿងនេះជាស្នាដៃមួយដែលបានទទួលការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកសិក្សាខ្មែរទូទៅ។ តាមដំណើររឿងបានរៀបរាប់ពីការមានសមត្ថភាពខ្ពស់មានចំណេះដឹងប្រកបដោយចរិយាសម្បត្តិក្នុងការដោះស្រាយបញ្ហា។ នាងគឺជានារីម្នាក់ដែលមានភាពរួសរាយរាក់ទាក់ ចេះមានការប្រាស្រ័យទាក់ទងល្អជាមួយញាតិមិត្តជិតខាង ជាមេគ្រួសារល្អដែលចេះទុកដាក់ថែរក្សា គ្រប់គ្រងទ្រព្យសម្បត្តិនានា

នៅក្នុងផ្ទះ។ នាងជាអ្នកអប់រំ ជាអ្នកដឹកនាំ ជំរុញលើកទឹកចិត្ត និងជួយទំនុកបម្រុងស្វាមីដែលជាមនុស្សល្ងង់ខ្លៅឱ្យក្លាយជាអ្នកមានទ្រព្យសម្បត្តិ ក្លាយជាមន្ត្រីដែលមានបុណ្យសក្តិ កិត្តិយសខ្ពង់ខ្ពស់ឧត្តុង្គឧត្តម (មាយើងមានយស ឧត្តមខ្ពង់ខ្ពស់ ត្បិតតែករិយា យសយឺនពណ្ណរាយ កេរ្តិ៍ឆ្ងាយសោះសា ប្រាកដប្រុងប្រា កបកេរ្តិ៍វែងឆ្ងាយ។)[១៧]

មាណពមាយើងដំបូងឡើយជាមនុស្សក្រីក្រ លំបាកវេទនា ព្រោះមានប្រពន្ធជាស្រីខាតលក្ខណ៍ តែបន្ទាប់ពីបានប្តូរប្រពន្ធខាតលក្ខណ៍ជាមួយនឹងនាយកេត្រាមក ថៅមាណពតែងតែស្តាប់តាមសំដីណែនាំរបស់នាងជាករិយាក្រោយដែលជាស្ត្រីគ្រប់លក្ខណ៍ ពោរពេញដោយភាពប៉ិនប្រសប់ទាំងការងារក្នុងផ្ទះនិងការងារក្រៅផ្ទះជានិច្ច មិនដែលហ៊ានជំទាស់តវ៉ាអ្វីឡើយ រហូតចុងក្រោយក្លាយជាអ្នកមានទ្រព្យសម្បត្តិ និងបុណ្យសក្តិដោយសារតែនាងប្រពន្ធជួយដឹកនាំចាត់ចែងទំនុកបម្រុងសព្វយ៉ាង។ ដើមឡើយកាលមិនទាន់ក្លាយជាអ្នកមាន ជីវភាពគ្រួសារមាយើងនៅខ្វះខាតលំបាក ខ្វះមុខ ខ្វះក្រោយ។ លុះពេលថៅមាណពបានទៅកាប់ឧសក្នុងព្រៃ ដែលឧសនោះសុទ្ធតែឈើប្រណិតមានតម្លៃ ជាហេតុនាំឱ្យនាងជាប្រពន្ធក្រោយដែលជាស្ត្រីឆ្លាតវាងវៃ ស្គាល់ប្រភេទឈើល្អនិងមានតម្លៃក៏បង្គាប់ឱ្យប្តីទៅប្រមូលកាប់ឈើនោះយកមកទុកឱ្យបានច្រើន។ ដោយស្តាប់តាមបង្គាប់របស់ប្រពន្ធ បុរសជាប្តីមិនបង្អង់យូរក៏ទៅកាប់ឈើយកមកទុកយ៉ាងច្រើនសន្ធឹកសន្ធាប់។ នាងប្រពន្ធបានចាត់ចែងយកឈើលក់ទៅឱ្យពួកឈ្មួញរហូតក្លាយជាអ្នកមានទ្រព្យស្តុកស្តម្ភ និងទទួលបាននូវការរាប់អានពីបងប្អូនញាតិមិត្តទាំងឡាយ (ឈើនេះខ្ញុំស្គាល់ ជាក់ឥតពិភាល់ អស់អ្នកសំពៅ គេទិញមិនលែង ខ្ញុំឯងឃើញនៅ គេទិញនាំទៅ ឯស្រុកចិនណា។ បើយើងបានហើយ យើងគិតអ្វីឡើយ លក់តែគ្រឹស្នា ក្តាំពាក់ប្រពៃ យកថ្លៃមកណា ទិញព្រៃកាសា សំពត់ជាតី។)[១៨]

ត្រង់នេះបានបង្ហាញពីគំនិតដ៏ប៉ិនប្រសប់ក្នុងការចេះចាត់ចែងការងារ និងទ្រព្យសម្បត្តិក្នុងផ្ទះព្រមទាំងចេះប្រាស្រ័យទាក់ទងជួញដូរ រកស៊ីជាមួយអ្នកផង

[១៧] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរភាគ៤* រឿងមាយើង ទំ.៥៤។

[១៨] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរភាគ៤* រឿងមាយើងទំ.២៦។

ទាំងឡាយរបស់ស្ត្រី ធ្វើឱ្យគ្រួសារកាន់តែរីកចម្រើនទៅមុខជាលំដាប់ៗ ក្នុងន័យនេះ ស្ត្រីដែលមានភាពជាអ្នកដឹកនាំចេះចាត់ចែងការងារត្រូវតែមានភាពឈ្លាសវៃ យល់សាច់ការ ដឹងពក់ជ្រៅ និងច្បាស់លាស់ក្នុងការងារៗ មិនមែនត្រឹមតែចង់ឱ្យគ្រួសារ និងប្តីមានតែទ្រព្យសម្បត្តិប៉ុណ្ណោះទេ តែនាងជាប្រពន្ធគឺចង់ដឹកនាំប្តីឱ្យក្លាយជាអ្នកមានបុណ្យសក្តិថែមទៀត ទើបស្ត្រីជាភរិយាតែងតែបង្គាប់ដឹកនាំប្តី និងលើកទឹកចិត្តឱ្យប្តីហ្វឹកហាត់ការរត់តែរាល់ៗថ្ងៃ ទោះបីជាដំបូងមានការលំបាកយ៉ាងណាក៏នាងជាប្រពន្ធនៅតែលើកទឹកចិត្តដឹកនាំប្តីជានិច្ច រហូតទាល់តែរត់យូរៗទៅលែងដឹងហត់ ដែលនាងធ្វើបែបនេះគឺក្នុងគោលបំណងដើម្បីឱ្យប្តីមានសុខភាពល្អ និងអាចទៅនៅបម្រើព្រះមហាក្សត្របានៗ ទោះបីជាហត់យ៉ាងណាក៏ដោយចៅមាណពមិនជំទាស់អ្វីទាំងអស់ គិតតែពីប្រឹងរត់យ៉ាងណាឱ្យទាល់តែសម្រេចតាមបំណងរបស់ខ្លួន និងភរិយាៗ ស្ត្រីជាភរិយាបានចាត់ចែងគ្រប់កិច្ចការ ទាំងបាយទឹក នំចំណីបម្រុងឱ្យប្តីជាស្រេច មិនឱ្យមានខ្វះចន្លោះឡើយ(លុះប្តីនាងរត់ រត់រួចពុំហត់ ដោយចិត្តស្មោះសា ឯនាងនារី យល់ប្តីអាត្មា បរិបូណ៌ហើយណា ទើបនាងឆាប់ក្រៃៗ ទៅថ្កានមន្ត្រីឱ្យគេថ្វាយប្តី ជាខ្ញុំក្សត្រថ្លៃ មន្ត្រីនាំថ្វាយ ដូចចិត្តនាងវៃបម្រើសព្វថ្ងៃ ជាខ្ញុំរាជាៗ)[១៩] នេះសរបញ្ជាក់ឱ្យឃើញពីភាពដឹកនាំរបស់ស្ត្រី និងឥទ្ធិពលស្ត្រីក្នុងការគ្រប់គ្រងចាត់ចែងដឹកនាំក្នុងគ្រួសារ និងការគោរពឱ្យតម្លៃរបស់ស្វាមីចំពោះភរិយា ទើបដឹកនាំគ្រួសារទៅរកតែភាពរីកចម្រើន និងសុភមង្គលៗ អ្វីៗដែលបានមកទាំងទ្រព្យសម្បត្តិ បុណ្យសក្តិគឺមិនមែនបានមកដោយឯកឯងគ្មានការខិតខំប្រឹងប្រែងនោះទេ តែរបស់ទាំងនោះបានមកដោយសារតែបញ្ញាញាណរបស់ស្ត្រី ជាភរិយាក្នុងការដឹកនាំ ផ្តួចផ្តើមដល់ស្វាមីដែលខ្វះនូវបញ្ញា និងការខិតខំរបស់ស្វាមីគួបផ្សំគ្នាផង នោះទើបនាំឱ្យស្វាមីក្លាយមកជាមនុស្សមានភាពរីកចម្រើនរុងរឿងប្រកបដោយទ្រព្យសម្បត្តិ និងកិត្តិយស សមដូចច្បាប់ព្រះរាជសម្ភារចែងថា "ខ្លែងហើរត្បិតខ្យល់ នាយថ្កើងត្បិតពល រក្សាឱ្យសុខទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក ផ្ទះធំ

---

[១៩] ពុទ្ធសាសនបណ្ឌិត *ប្រជុំរឿងព្រេងខ្មែរ ភាគ៤* រឿងមាយើង ទំ.២៨ៗ

ស្រណុកត្បិតកិរិយាជា" មានន័យថាគ្រួសារ
រុងរឿងអាស្រ័យប្រពន្ធជួយដឹកនាំជ្រោមជ្រែង។

បើយើងមើលមួយភ្លែតទៅ យើងយល់ថានៅក្នុងសង្គមខ្មែរយើង ស្ត្រីមានតួនាទីត្រឹមតែមើលថែកូន ថែផ្ទះ និងបម្រើស្វាមី គ្មានឋានៈ និងតួនាទីអ្វីធំដុំនៅក្នុងសង្គមដូចជាបុរសនោះទេ តែជាតុពិត ស្ត្រីមិនត្រឹមតែជាអ្នកដឹកនាំចាត់ចែងគ្រប់គ្រងក្នុងគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែតួនាទីរបស់ស្ត្រីគឺសំខាន់លើសពីនេះទៅទៀត សកម្មភាពស្ត្រី មិនមែននៅតែមួយកន្លែងតាមការបុរេនិច្ឆ័យរបស់បុរសដែលថាស្ត្រីគ្មានការងារអ្វីធំដុំក្រៅពីមើលថែកូន ដាំបាយ លាងចាន បោស ជូតផ្ទះ មិនអាចធ្វើការងារអ្វីសំខាន់ក្រៅពីនេះឡើយ តែការពិតស្ត្រីមានសមត្ថភាពខ្ពស់ក្នុងការចូលរួមដឹកនាំគ្រួសារ និងសង្គមស្មើនឹងបុរសដែរ។ ស្ត្រីមានប្រាជ្ញាឈ្លាសវៃ មានគំនិតច្នៃប្រឌិត មានការសហការសាមគ្គី ជាពិសេសគឺ ស្ត្រីមានសមត្ថភាពក្រោកឈរតស៊ូ រើបម្រះពីការគាបសង្កត់ជិះជាន់ និងការរើសអើងពីសំណាក់បុរស។

ម្យ៉ាងវិញទៀតស្ត្រីដែលមានសមត្ថភាពក៏ត្រូវបានគេផ្តល់ឱកាសឱ្យក្លាយជាអ្នកដឹកនាំគ្រប់គ្រងក្នុងប្រទេសមួយ ឬស្ថាប័នមួយចំនួន។ ជាតឹកតាងនៅសម័យមហានគរ មហេសីទី២ របស់ព្រះបាទជ័យវរ្ម័នទី៧ គឺព្រះនាងឥន្ទ្រទេវី ក៏ជាស្ត្រីឆ្នើមមួយរូប ដែលបានជួយស្វាមីក្នុងការរៀបចំផ្នែកសេដ្ឋកិច្ច នយោបាយ និងការដឹកនាំប្រទេសឱ្យកាន់តែមានភាពរីកចម្រើន ថែមទាំងជាស្ត្រីទី១ដែលចេះភាសាសំស្ក្រឹតយ៉ាងស្ទាត់ជំនាញ ព្រមទាំងជាអ្នកនិពន្ធដ៏ឆ្នើម និងជាសាកលវិទ្យាធិការិនីនៃសាកលវិទ្យាល័យជ័យស្រី នាសម័យអង្គរផងដែរ។ នេះសរបញ្ជាក់ថា ស្ត្រីពិតជាមានសមត្ថភាពអាចក្លាយជាអ្នកដឹកនាំបាន។ ជាងនេះទៅទៀត ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ពីឥទ្ធិពលរបស់ស្ត្រី តាមរយៈការលើកតម្កើងស្ត្រី ជាអ្នកដឹកនាំ ជាអ្នកគ្រប់គ្រងនោះ យើងគួរតែមើលពីអតីតកាលនៃការកកើតទឹកដីខ្មែរដំបូងដែលមានបឋមក្សត្រដឹកនាំប្រទេស គឺជាស្ត្រី ព្រះនាងសោមា ឬនាងនាគ។ មិនត្រឹមតែមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្របានចងក្រងអំពីបឋមក្សត្ររូបនេះទេ តែនៅក្នុងរឿងព្រេងខ្មែរទាក់ទងទៅនឹងទំនៀមទម្លាប់នៃការរៀបអាពាហ៍ពិពាហ៍ក៏មាន កូនប្រុសត្រូវតោងស្បៃកូនក្រមុំចូលក្នុងបន្ទប់ ឬគេតែងហៅថារឿងព្រះថោងនាងនាគ ក៏បានបង្ហាញអំពីការគោរពចំពោះស្ត្រីដែរ។

យ៉ាងណាមិញរឿងប្រវត្តិឃុំវាលជួបក៏បង្ហាញពីតម្លៃស្ត្រីតាមរយៈភាពជាអ្នកដឹក

នាំដែរ ព្រោះស្ត្រីមានសមត្ថភាពទាមទារពីបញ្ហាទំនៀមទម្លាប់ប្រពៃណីដែលបុរសត្រូវចូលដណ្ដឹងស្រី ហើយត្រូវយកថ្លៃបណ្ណាការទៅជូនខាងស្រី។ សាច់រឿងបង្ហាញពីលក្ខណៈរបស់ស្ត្រីដែលមានភាពឈ្លាសវៃ តស៊ូព្យាយាម អំណត់អត់ធន់នឹងការងារ សាមគ្គីគ្នា និងមានភាពជាអ្នកដឹកនាំ ទោះបីដឹងថាខ្លួនមានកម្លាំងខ្សោយជាងបុរសក៏ដោយ តែដើម្បីរើបម្រះពីភាពលំបាកដែលខ្លួនបានជួបប្រទះក្នុងការរស់នៅ ទើបធ្វើឱ្យមានគំនិតផ្តួចផ្តើមរិះរកមធ្យោបាយទប់ទល់ជាមួយបុរស ដើម្បីទាមទារទំនៀមទម្លាប់ឱ្យបុរសទៅដណ្ដឹងស្រី ហើយយកជំនូនជូនខាងស្រី គឺបង្ហាញពីការឱ្យតម្លៃស្ត្រី ព្រមទាំងដើម្បីលើកស្ទួយឧត្តមភាពរបស់ខ្លួនជាស្ត្រីឱ្យបានប្រសើរឡើង។ ដោយសារដឹងថាខ្លួនជាភេទដែលមានកម្លាំងខ្សោយមិនអាចនឹងតតាំងជាមួយបុរសក្នុងប្រើកម្លាំងបាន ទើបស្ត្រីបានប្រើប្រាស់ប្រាជ្ញាដ៏ភ្លឺថ្លារបស់ខ្លួនដើម្បីជាអាវុធយកឈ្នះលើបុរស។ ទាំងនេះបានសរបញ្ជាក់ឱ្យឃើញថាស្ត្រី ជាភេទទន់ខ្សោយក៏ពិតមែនតែនាងមានគំនិតផ្តួចផ្តើមដឹកនាំ ព្រមទាំងអាចយកឈ្នះបុរសៗដែលមានកម្លាំងខ្លាំងដោយសារសមត្ថភាព ប្រាជ្ញាស្មារតី ការច្នៃប្រឌិត គួបផ្សំនិងកម្លាំងសាមគ្គីដ៏ក្លាវក្លា និងការខិតខំប្រឹងប្រែងតស៊ូរបស់ស្ត្រី ទើបធ្វើឱ្យពួកគេអាចទទួលបានជោគជ័យសមតាមបំណងប្រាថ្នារបស់ខ្លួន (តួអង្គជូនមើចជូនពៅង បានដឹកនាំក្រុមខ្លួនធ្វើការប្រយុទ្ធជាមួយបក្សពួកស្តេចប្រទាលរហូតទទួលបានជ័យជម្នះ)។

ស្ត្រីជាអ្នកមានទឹកចិត្តជួយស្វាមីដើម្បីទទួលបានបុណ្យសក្តិ ឋានៈខ្ពង់ខ្ពស់មាននៅក្នុងរឿងមាយើង រឿងគង់ហ៊ាន និងរឿងដើមរលួសមាស ស្ត្រីមានការតស៊ូជម្នះរាល់ទង្វើ សកម្មភាពដែលខ្លួននាងបានជួបប្រទះ ស្ត្រីមានតួនាទីជាច្រើននៅ។

ក្នុងរឿង**តាបសល្ងួចមាស** បានបង្ហាញពីភាពឈ្លាសវៃរបស់បុត្រីស្តេចដែលចេះជួយដោះស្រាយបញ្ហាឱ្យស្តេចផែនដីក្នុងការស្វែងរកយុត្តិធម៌ឱ្យប្រជារាស្ត្រទូទៅក៏ដូចជាតាបសទាំង៤ និងបុរសម្ចាស់មាស។

ម្យ៉ាងវិញទៀតនៅក្នុងរឿងកណ្ដុរសឡើងធ្វើស្តេច ក៏បានបង្ហាញឱ្យឃើញពីការតបគុណការដឹងគុណរបស់នាងទាំង១២ចំពោះអ្នកដែលបានធ្វើគុណចំពោះនាង ហើយក៏បានបង្ហាញពីភាពកតញ្ញូរបស់កូនស្រី បើទោះបីជាម្ដាយឪពុកបោះបង់ចោលនាងក៏ដោយ នាងនៅតែស្វែងរក និងព្យាយាមស្វែងរកគ្រប់មធ្យោបាយដើម្បីរស់នៅ និងដើម្បីក្លាយជាកូនល្អ កិរិយាល្អ និង

ប្រជារាស្ត្រល្អជាដើម។ ម្យ៉ាងវិញទៀតស្ត្រីក៏ជាអ្នកចូលរួមក្នុងការអភិរក្សនូវវប្បធម៌ប្រពៃណីទំនៀមទម្លាប់ ជាស្ត្រីដឹកនាំគ្រួសារដ៏ពូកែសម្រាប់ស្វាមី និងបុត្រធីតា ស័ក្តិសមជាស្ត្រីដែលគួរឱ្យលើកតម្កើង គោរព និងផ្តល់តម្លៃក្នុងភាពជាអ្នកដឹកនាំ។

សរុបសេចក្តីមកតាមរយៈការសិក្សាអក្សរសិល្ប៍ប្រជាប្រិយខ្មែរ ជាពិសេសតំណាលកថាប្រជាប្រិយដែលយើងបានដកស្រង់យកមកសិក្សាពិតជាបានបង្ហាញយ៉ាងច្បាស់ពីលក្ខណៈសម្បត្តិរបស់ស្ត្រីខ្មែរ ដែលជាស្ត្រីពោរពេញទៅដោយចំណុចជាវិជ្ជមាន នោះគឺស្ត្រីខ្មែរមានភាពទន់ភ្លន់ តែរឹងមាំ ចេះបត់បែនខ្លួនទៅតាម កាលៈទេសៈ មានភាពឈ្លាសវៃ ប៉ិនប្រសប់គ្រប់កិច្ចការ មានកត្តិភាព ជាស្ត្រីក្លាហាន ចេះសម្គាល់លក្ខណៈរបស់មនុស្សប្រុស ចេះប្រើវិធីសាស្ត្រយករួចខ្លួនចេញផុតពីការបៀតបៀនរាងកាយពីពួកចោរ ចេះតស៊ូគ្រប់កាលៈទេសៈដើម្បីទទួលបានជោគជ័យជម្នះរាល់ឧបសគ្គ ប្រើប្រាស់បញ្ញាដែលខ្លួនមានសម្រាប់ដោះស្រាយបញ្ហាជីវភាព ប្រើប្រាស់រូបសម្បត្តិរបស់ខ្លួនដើម្បីស្វែងរកសុភមង្គល ស្ត្រីអាចក្លាយជាអ្នកដឹកនាំក្រុម ឬបក្សពួកខ្លួនបានល្អ។ **(នៅមានត)**